**<u>បទអន្តរាគមន៍</u>**
**ស្តីពី**
**សំណើ សំណូមពរ ក្តីកង្វល់ អនុសាសន៍ និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ**
**លោកស្រី ស៊ិន ពុទ្ធារី**
**នាយិកាប្រតិបត្តិនៃអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា (គ ស ក)**
**ថ្លែងក្នុងកម្មវិធី**
**វេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (លើកទី៦)**
**ថ្ងៃទី <u>១១ ខែធ្នូ ឆ្នាំ២០២៤ នៅទីស្តីការក្រសួងមហាផ្ទៃ រាជធានីភ្នំពេញ</u>**

**សូមគោរព៖**

ជាបឋម នាងខ្ញុំសូមគោរព

- **ឯកឧត្តម ម៉ិន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាល ជាតំណាងដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ជាទីគោរព
- ឯកឧត្តម លោកជំទាវ តំណាងក្រសួង ស្ថាប័ន នៃរាជរដ្ឋាភិបាល
- ឯកឧត្តម លោកជំទាវ អភិបាល នៃគណៈអភិបាលរាជធានី ខេត្ត
- លោក លោកស្រី អ្នកនាងកញ្ញា តំណាងសមាគម អង្គការមិនមែនរដ្ឋាភិបាលក្នុងស្រុក និងបរទេស តំណាងបណ្តាញថ្នាក់ខេត្ត ដៃគូអភិវឌ្ឍន៍ ជាភ្ញៀវជាតិ និងអន្តរជាតិ ជាទីគោរពរាប់អាន។

ថ្ងៃនេះ នាងខ្ញុំមានកិត្តិយសដ៏ខ្ពង់ខ្ពស់ និងសេចក្តីសោមនស្សរីករាយយ៉ាងក្រៃលែង ដោយទទួលបានការអនុញ្ញាតពី **ឯកឧត្តមអភិសន្តិបណ្ឌិត ស សុខា ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ** និង**ឯកឧត្តម ម៉ិន ហុន** រដ្ឋលេខាធិការក្រសួងមហាផ្ទៃ និងជាប្រធានក្រុមការងាររបស់រាជរដ្ឋាភិបាល អនុញ្ញាតឱ្យនាងខ្ញុំឡើងថ្លែង បទអន្តរាគមន៍ ស្តីពី សំណើ សំណូមពរ ក្តីកង្វល់ អនុសាសន៍ និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ក្នុងកម្មវិធីវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (លើកទី៦) ដ៏មានសារៈសំខាន់នាថ្ងៃនេះ។

តាងនាមអង្គការគណៈកម្មាធិការសហប្រតិបត្តិការដើម្បីកម្ពុជា ដែលមានអង្គការក្នុងស្រុក និងបរទេសជាង២០០ ស្ថាប័ន ជាអង្គការសមាជិក បានបង្កើតឡើងក្នុងឆ្នាំ១៩៩០ ក្នុងតួនាទីជាអង្គភាពលេខាធិការដ្ឋាន បានធ្វើការសហការជាមួយអង្គការសម្ព័ន្ធភាពជាដៃគូក្នុងការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យ (សម្ព័ន្ធភាព CPDD) រួមទាំងអង្គការមិនមែនរដ្ឋាភិបាលដែលធ្វើការលើវិស័យ អប់រំ សុខាភិបាល បរិស្ថាន ស្ត្រី កុមារ និងយេនឌ័រ សមាជិកបណ្តាញថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងក្នុងនាមខ្លួនខ្ញុំផ្ទាល់ ខ្ញុំសូមសំដែងនូវការគោរព កោតសរសើរចំពោះថ្នាក់ដឹកនាំរបស់ក្រសួងមហាផ្ទៃដែលបានរៀបចំវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (លើកទី៦) នេះឡើង។

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី គណៈអធិបតី ភ្ញៀវកិត្តិយសទាំងអស់ជាទីមេត្រី!**

នាងខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះក្រសួងមហាផ្ទៃដែលបានយកចិត្តទុកដាក់ ក្នុងការលើកកម្ពស់កិច្ចសហប្រតិបត្តិការ តាមរយៈការរៀបចំវេទិកាស្តីពីភាពជាដៃគូ(លើកទី១) កាលពីថ្ងៃទី២១ ខែមិថុនា ឆ្នាំ២០១៨ និងជាបន្តបន្ទាប់រហូតដល់វេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិល (លើកទី៦) នាថ្ងៃនេះ។

ជាពិសេស **ក្រសួងមហាផ្ទៃ** នៅតែបន្ត និងជំរុញរដ្ឋបាលថ្នាក់ក្រោមជាតិ មន្ទីរ ស្ថាប័នដែលពាក់ព័ន្ធ ពង្រឹងកិច្ចសហប្រតិបត្តិការជាមួយសង្គមស៊ីវិលនៅថ្នាក់ក្រោមជាតិ ដើម្បីរៀបចំវេទិកាពិគ្រោះយោបល់ជាមួយសមាគម អង្គការមិនមែន

រដ្ឋាភិបាលនិងសហាគមន៍នានាដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត ពីរដង (២ដង ) ក្នុងមួយឆ្នាំ ដូចវេទិកាថ្នាក់ជាតិដែរ។

តាមរយៈវេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ និងក្រោមជាតិនាពេលកន្លងមក គឺពិតជាមានសារៈសំខាន់ និងបានឆ្លើយតបតាមសំណើ និងសំណូមពររបស់អង្គការសង្គមស៊ីវិលបានច្រើនដែលក្នុងនោះមាន **ការបង្កើតនូវយន្តការនានា កិច្ចប្រជុំអន្តរក្រសួង កិច្ចប្រជុំក្រុមការងារកម្រិតបច្ចេកទេសជាដើម** ក្នុងការដោះស្រាយបញ្ហាប្រឈម និងសំណើនិងសំណូមពរដែលបានលើកឡើងទាំងអស់នោះ។

ទន្ទឹងគ្នានេះផងដែរ នាងខ្ញុំក៏សូមអបអរសាទរផងដែរដល់រាជរដ្ឋាភិបាលកម្ពុជា នីតិកាលទី៧ នៃរដ្ឋសភា បានដាក់ចេញនូវគោលនយោបាយ រក្សាសុខសន្តិភាព ស្ថិរភាព និងការអភិវឌ្ឍសង្គម-សេដ្ឋកិច្ចជាមួយនឹងឆន្ទៈសម្រេចឱ្យបាននូវចក្ខុវិស័យ ជំរុញកម្ពុជាទៅជាប្រទេស មានចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០ និងជាប្រទេសចំណូលខ្ពស់នៅឆ្នាំ២០៥០ ដោយបានដាក់ចេញនូវ យុទ្ធសាស្ត្របញ្ចកោណ ដើម្បី កំណើន ការងារ សមធម៌ ប្រសិទ្ធភាព និងចីរភាព ដែលក្នុងនោះ គឺការលើកកម្ពស់ការអនុវត្តអភិក្រម ឆ្លុះកញ្ចក់ ងូតទឹក ដុសក្អែល ព្យាបាល និងវះកាត់ និងអភិក្រម ជវភាពនៃប្រព័ន្ធតួអង្គតែមួយ ពោលគឺការអភិវឌ្ឍស្ថាប័ន ការពង្រឹង អភិបាលកិច្ចល្អ និងការពង្រីកប្រសិទ្ធភាពការងារក្នុងវិស័យសាធារណៈ។

បើយោងតាមរបាយការណ៍របស់រាជរដ្ឋាភិបាល នៅដើមអាណត្តិទី៧នេះ  នាងខ្ញុំសូមចូលរួមអបអរសាទរចំពោះរាជរដ្ឋាភិបាលកម្ពុជា ដែលបានសម្រេចបាននូវលទ្ធផលធំៗ ដូចជា ការរក្សាបាននូវកំណើនសេដ្ឋកិច្ច ការជំរុញ និងកៀរគរធុរជន និងការវិនិយោគ ការលើកកម្ពស់សុខុមាលភាពរបស់ប្រជាពលរដ្ឋ និងមន្ត្រីរាជការ ព្រមទាំងការធ្វើកំណែទម្រង់គ្រប់វិស័យ រួមមាន ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យុត្តិធម៌និងតុលាការ និងការគ្រប់គ្រងរដ្ឋបាលសាធារណៈ ដែលផ្តោតសំខាន់លើគុណភាព ប្រសិទ្ធភាព ទំនើបកម្ម និងការអភិវឌ្ឍប្រកបដោយចីរភាព។

តាមរយៈការដាក់ចេញនូវគោលនយោបាយ និង យុទ្ធសាស្ត្របញ្ចកោណ និងការសម្រេចបាននូវលទ្ធផលធំៗដូចជាដែលបានរៀបរាប់ខាងលើ កំណែទម្រង់នានាជាច្រើនត្រូវបានរៀបចំឡើង ដែលបាន និងកំពុងជំរុញការអនុវត្ត ពិសេសកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការនៅកម្ពុជា តាមរយៈការរៀបចំអនុវត្តកម្មវិធីជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដំណាក់កាលទី២ (២០២១-២០៣០)។

**ហើយនៅក្នុងឯកសារទស្សនទាន និងគោលនយោបាយទាំងអស់ដែលបានរៀបរាប់ជូន តែងបានរំលេច នូវតួអង្គអភិវឌ្ឍន៍ទាំងអស់ ដែលមិនអាចខ្វះបាន ដែលក្នុងនោះមានការដាក់បញ្ចូល និងការរំលេចអំពីតួនាទីដ៏សំខាន់របស់អង្គការសង្គមស៊ីវិលក្នុងការចូលរួមក្នុងការអភិវឌ្ឍប្រកបដោយចីរភាពក្នុងប្រទេសកម្ពុជាផងដែរ។**

**ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី គណៈអធិបតី ភ្ញៀវកិត្តិយសទាំងអស់ជាទីគោរពរាប់អាន!**

វេទិកាស្តីពីភាពជាដៃគូរវាងរាជរដ្ឋាភិបាល និងអង្គការសង្គមស៊ីវិលនៅថ្នាក់ជាតិ និងក្រោមជាតិ ជាបរិយាកាសដ៏ថ្លៃថ្លាមួយសម្រាប់ភាគីពាក់ព័ន្ធទាំងអស់ មានឱកាសបានជួបជុំ  ពិភាក្សា ដើម្បីធ្វើការឆ្លុះបញ្ចាំងអំពីសមិទ្ធផលដែលសម្រេចបាន ការអនុវត្តល្អ បញ្ហាប្រឈម និងស្វែងរកដំណោះស្រាយរួមមួយ តាមរយៈការលើកកម្ពស់នូវស្មារតីនៃកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូ ប្រកបដោយបរិយាបន្ន និងសាមគ្គីភាព ដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព។

គួរកត់សម្គាល់ផងដែរថា **ក្រសួងមហាផ្ទៃ** ជានិច្ចកាល តែងតែសហការ និងធ្វើការឆ្លើយតបចំពោះបញ្ហាប្រឈមរបស់អង្គការសង្គមស៊ីវិលតាមរយៈការចូលរួមក្នុង**សិក្ខាសាលា វេទិកា ការប្រជុំ និងរៀបចំឱ្យមានជំនួបសំខាន់ៗនានា។**

ជាក់ស្តែងការឆ្លើយតបសំណើតាមរយៈក្រុមការងារបច្ចេកទេស វិសោធនកម្មច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ជាដើម។

បើទោះជាយ៉ាងនេះក្តី តាមរយៈកិច្ចសហប្រតិបត្តិការ ការអនុវត្តគម្រោងនានា នាពេលកន្លងមក និងក្នុងឆ្នាំ២០២៤នេះ អង្គការសង្គមស៊ីវិលសង្កេតឃើញថា អង្គការសង្គមស៊ីវិល នៅជួបប្រទះនូវបញ្ហាប្រឈមក្នុងប្រតិបត្តិការ ការអនុវត្តគម្រោង និងកាតព្វកិច្ចមួយចំនួនទៀតនៅតែបន្តកើតមានឡើង។

ដូច្នេះ ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំសូមការអនុញ្ញាតធ្វើការរៀបរាប់បញ្ហាទាំងនោះដូចសេចក្តីសង្ខេប ដោយសូមភ្ជាប់ជូនជាមួយសំណើ សំណូមពរ ក្តីកង្វល់ អនុសាសន៍ និងកិច្ចសហប្រតិបត្តិការក្នុងភាពជាដៃគូដែលបានប្រមូលពីអង្គការសមាជិក អង្គការដៃគូ និងអង្គការបណ្តាញទាំងថ្នាក់ជាតិ និងក្រោមជាតិ ធ្វើការបែងចែកតាមផ្នែកនីមួយៗ ដើម្បីជម្រាបជូនដូចខាងក្រោមនេះ៖

**បញ្ហាប្រឈមរួម**

១. ការចុះ និងបន្តអនុស្សារណៈនៃការយោគយល់គ្នា (MOU) សម្រាប់ការអនុវត្តគម្រោង និង/ឬសម្រាប់ស្ថាប័នរវាង**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលបរទេស**ជាមួយក្រសួងនានាមានបែបបទ និងស្តង់ដារផ្សេងៗគ្នាដែលធ្វើឲ្យមានការពិបាកក្នុងការអនុវត្ត។

២. អាជ្ញាធរនៅថ្នាក់ក្រោមជាតិមួយចំនួននៅតែតម្រូវឱ្យ**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**ក្នុងស្រុកចុះអនុស្សារណៈនៃការយោគយល់គ្នាសម្រាប់គម្រោង ឬស្ថាប័នរវាង**សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះ**ជាមួយមន្ទីរឬស្ថាប័ននៅខេត្តគោលដៅនៃប្រតិបត្តិការរបស់ខ្លួន ដែលមិនឆ្លើយតបទៅនឹងខ្លឹមសារនៃច្បាប់ស្តីពី**សមាគម និងអង្គការមិនមែនរដ្ឋាភិបាល**។

៣. ដំណើរការជូនដំណឹងអំពីការប្រែប្រួល ឬផ្លាស់ប្តូរប្រធាន/នាយកប្រតិបត្តិ ឬអាសយដ្ឋានរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលក្រសួងតម្រូវឱ្យសរសេរលិខិតជាលាយលក្ខណ៍អក្សរជាក់ជូនរដ្ឋមន្ត្រី និងឯកសារយោងច្រើនផ្សេងៗ ដែលតម្រូវសម្រាប់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនៅថ្នាក់ក្រោមជាតិ ចាំបាច់ត្រូវឡើងមកក្រសួងមហាផ្ទៃ ស្ថាប័នពាក់ព័ន្ធនានាក្នុងនោះមាន **អគ្គនាយកដ្ឋានពន្ធដារ និង និយ័តករគណនេយ្យនិងសវនកម្ម**។

៤. ស្ថាប័នមួយចំនួននៅថ្នាក់ជាតិ និងក្រោមជាតិ នៅតែតម្រូវឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដាក់លិខិតជូនដំណឹងជាលាយលក្ខណ៍អក្សរ ឬលិខិតស្នើសុំកិច្ចសហប្រតិបត្តិការ ទោះបីសមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះបានចុះបញ្ជី និងអនុស្សារណៈនៃការយោគយល់រួចហើយក៏ដោយ។ ការតម្រូវនេះ គឺផ្ទុយទៅនឹងសេចក្តីជូនដំណឹងលេខ២០០៦សជណ **ចុះថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ២០១៨** របស់ក្រសួងមហាផ្ទៃ ដោយបានណែនាំរដ្ឋបាលថ្នាក់ក្រោមជាតិរបស់ខ្លួនមិនតម្រូវឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលដាក់លិខិតស្នើសុំអនុញ្ញាតដោយគ្រាន់តែជូនដំណឹង។ ក្នុងករណីខ្លះអាជ្ញាធរមិនឆ្លើយតបចំពោះលិខិតជូនដំណឹងរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះឡើយ។

៥. ស្ថាប័នមួយចំនួននៅថ្នាក់ជាតិ និងក្រោមជាតិ នៅតែបន្តចុះមកភ្លាមៗ ធ្វើការឃ្លាំមើល សាកសួរ ថតរូប វីដេអូ ថតយកបញ្ជីវត្តមានអ្នកចូលរួម ថតចម្លងឯកសារ ថតសំឡេងរបស់អ្នកចូលរួមក្នុងសិក្ខាសាលាឬវេទិកាសាធារណៈ និងកិច្ចប្រជុំ និងពេលខ្លះតាមរយៈការតម្រូវឱ្យបុគ្គលិកភោជនីយដ្ឋាន និងសណ្ឋាគារឯកជន ធ្វើការរាយការណ៍ទៅប៉ូលីស និងអាជ្ញាធរមូលដ្ឋានផងដែរ។

៦. អាជ្ញាធរមូលដ្ឋានដូចជា មេភូមិ មេឃុំ ឬមន្ទីរ អាជ្ញាធរទាំងនោះតម្រូវឱ្យសមាគម និងអង្គការមិនមែនរដ្ឋាភិបាលត្រូវតែដាក់លិខិតទៅស្នើសុំពីអភិបាលខេត្ត ទើបគាត់មកចូលរួមកម្មវិធី ដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាលបានអញ្ជើញគាត់ និងការសហការផ្សេងៗទៀត។ ក្នុងករណីខ្លះ អាជ្ញាធរមិនឆ្លើយតបចំពោះ លិខិតអញ្ជើញរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិបាលនោះឡើយ។

**សំណូមពររបស់សង្គមស៊ីវិល**

១)ស្នើសុំបន្ត និងជំរុញរដ្ឋបាលថ្នាក់ជាតិក្រោមជាតិ ស្ថាប័នដែលពាក់ព័ន្ធ អនុវត្ត និងពង្រឹងកិច្ចសហការរៀបចំវេទិកាពិគ្រោះយោបល់ជាមួយសមាគម អង្គការមិនមែនរដ្ឋាភិបាលនិងសហគមន៍នានាដែលធ្វើសកម្មភាពក្នុងដែនសមត្ថកិច្ចរបស់រដ្ឋបាលរាជធានី ខេត្ត យ៉ាងតិច ២ ដងក្នុងមួយឆ្នាំ ដើម្បីទទួលយកសំណូមពរ អនុសាសន៍ និងដើម្បីដោះស្រាយបញ្ហាប្រឈមនានា ដែលបានកើតឡើង

២) ស្នើសុំ រាជរដ្ឋាភិបាល និងអាជ្ញាធរថ្នាក់ជាតិ បន្ត និងពង្រឹង ការអប់រំ ការផ្សព្វផ្សាយសេចក្តីណែនាំលិខិតបទដ្ឋានគតិយុត្តនានាឱ្យបានទូលំទូលាយទៅរដ្ឋបាល ឬអាជ្ញាធរថ្នាក់ក្រោមជាតិដើម្បី ពង្រឹងកិច្ចសហការជាមួយអង្គការសង្គមស៊ីវិលតាមរយៈការអនុវត្តច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល។

៣) ស្នើសុំរាជរដ្ឋាភិបាល ពង្រឹង បន្តការគាំទ្រ និង លើកកម្ពស់សិទ្ធិ និងសេរីភាពនៃការបញ្ចេញមតិ ការជួបប្រជុំដោយសន្តិវិធី និងសិទ្ធិទទួលបានព័ត៌មានរបស់ប្រជាពលរដ្ឋគ្រប់រូប ដែលមានចែងក្នុងរដ្ឋធម្មនុញ្ញ នៃព្រះរាជាណាចក្រកម្ពុជា និងសិទ្ធិ សេរីភាពដូចដែលបានកំណត់ដោយច្បាប់ស្តីពីសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ដើម្បី បរិយាកាសអំណោយផលដល់ការធ្វើសកម្មភាពផ្សេងៗ និង បញ្ចៀសការទាញភ្ជាប់សង្គមស៊ីវិលជាមួយគណបក្សនយោបាយនានា។

៤) ស្នើសុំរាជរដ្ឋាភិបាល ក្រសួងមហាផ្ទៃ ក្រសួងសេដ្ឋកិច្ចហិរញ្ញវត្ថុ និងក្រសួងដែលពាក់ព័ន្ធផ្សេងៗទៀត សម្របសម្រួលផ្តល់ព័ត៌មាន ផ្តល់ឱកាសក្នុងការឆ្លើយតប ឬចូលឆ្លើយបំភ្លឺ ឬពិន័យរដ្ឋបាល ក្នុងករណីដែលសមាគម និងអង្គការមិនមែនរដ្ឋាភិបាល ខកខាន ឬមិនបានអនុវត្តកាតព្វកិច្ចរបស់ខ្លួនបានពេញលេញដូចមានចែងក្នុងច្បាប់ស្តីពីសារពើពន្ធ ច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម រួមទាំងកាតព្វកិច្ចផ្សេងៗទៀត។

៥) ស្នើសុំរាជរដ្ឋាភិបាលធ្វើសុខដុមរមនា និងសមាហរណកម្មការចុះ និងបន្តអនុស្សារណៈ នៃការយោគយល់គ្នា (MOU) សម្រាប់ការអនុវត្តគម្រោង និង/ឬសម្រាប់ស្ថាប័ន រវាងសមាគម និងអង្គការមិនមែនរដ្ឋាភិបរទេសជាមួយក្រសួងនានាតាមប្រតាមប្រព័ន្ធអនឡាញ និងជាប្រព័ន្ធតែមួយ។

៦) ការធ្វើបច្ចុប្បន្នភាព ការដាក់របាយការណ៍ប្រចាំឆ្នាំរបស់សមាគម និងអង្គការមិនមែនរដ្ឋាភិក្នុងស្រុក ជាមួយក្រសួងនានាតាមប្រតាមប្រព័ន្ធអនឡាញ និងប្រសិនបើមានការតម្រូវបង់សេវាផ្សេងៗ សូមមានតារាងសេវាសាធារណៈមានវិក្កយបត្រ ជៀសវាងការយកកម្រៃសេវាក្រៅផ្លូវការ ផ្សេងៗ។

នាងខ្ញុំសង្ឃឹមយ៉ាងមុតមាំថា ការលើកបញ្ហាប្រឈមរួមនេះឡើង ជាការស្នើសុំស្វែងរកដំណោះស្រាយរួម ក្នុងការអនុវត្តន៍ច្បាប់ និងគោលនយោបាយនានា ដែលអាចជួយដល់អង្គការសង្គមស៊ីវិលយើងខ្ញុំ ឱ្យបន្តតួនាទីរបស់ខ្លួនក្នុងការចូលរួមចំណែកដល់ការអភិវឌ្ឍប្រទេសជាតិនៃយើង។

នាងខ្ញុំមានជំនឿ និងក្តីសង្ឃឹមថា វេទិកាភាពជាដៃគូ នាថ្ងៃនេះ នឹងទទួលបាននូវផ្លែផ្កា តាមរយៈការពង្រីកកិច្ចសហប្រតិបត្តិការ ប្រកបដោយសាមគ្គីភាព នឹងរួមគ្នាក្នុងការបន្ត ការដោះស្រាយបញ្ហារួមឈានឆ្ពោះទៅសម្រេចនូវទស្សនវិស័យរួម។

ជាទីបញ្ចប់ ខ្ញុំសូមប្រសិទ្ធពរជ័យជូនគណៈអធិបតី ឯកឧត្តម លោកជំទាវ អស់លោក លោកស្រី អ្នកនាងកញ្ញាជាភ្ញៀវជាតិ និងអន្តរជាតិ ដែលកំពុងចូលរួម ក្នុងកម្មវិធីនេះ ឲ្យជួបតែពុទ្ធពរបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមគោរពថ្លែងអំណរគុណ និងសូមអរគុណ!**